# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចព្រមព្រៀង

**រវាង**

**តំណាងរោងចក្រ ឌីន លីង ហ្គាម៉ិន ឯ.ក**

**និង**

**ប្រតិភូបុគ្គលិក**

**ស្តីអំពីការព្យួរកិច្ចសន្យាការងារ**

នៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២៤ វេលាម៉ោង៩ និង៣០នាទី នៅក្នុងរោងចក្រ **ឌីន លីង ហ្គាម៉ិន ឯ.ក** មានទីតាំងផ្លូវខ្វាងរៀប២ ភូមិដំណាក់ធំ៣ សង្កាត់ស្ទឹងមានជ័យទី៣ ខណ្ឌមានជ័យ ក្រុងភ្នំពេញ មានកិច្ចប្រជុំមួយរវាងតំណាងក្រុមហ៊ុន និងប្រតិភូបុគ្គលិក និងប្រធានផ្នែកតាមក្រុមនីមួយៗ ស្តីអំពីការព្យួរកិច្ចសន្យាការងារ ។

នៅក្នុងអង្គប្រជុំនេះ តំណាងក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិតទាំងអស់អំពីស្ថានភាពបច្ចុប្បន្ននៅក្នុងរោងចក្រថា ដោយសារជួបវិបត្តិសេដ្ឋកិច្ចជាសកល ក្រុមហ៊ុនយើងពុំមានការបញ្ជាទិញដែលមិនអាចអោយចង្វាក់ផលិតកម្មរបស់រោងចក្រដំណើរការបាន ហេតុដូចនេះ ក្រុមហ៊ុនសម្រេចធ្វើការព្យួរកិច្ចសន្យាការងារកម្មករ និយោជិតចំនួន**៦៨២នាក់** ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន **៦៨២នាក់** (ស្រី៦១៤នាក់ ) រយៈពេលចំនួន**៥៣ថ្ងៃ** គឺចាប់ពី **ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២៤ រហូតដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ ២០២៤** ។

តំណាងប្រតិភូបុគ្គលិក និងកម្មករនយោជិតយល់ព្រមទទួលយកប្រាក់ឧបត្ថម្ភចំនួន **៥០%នៃប្រាក់ខែគោល** ដែលក្រុមហ៊ុនផ្តល់ឲ្យក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារនេះ ។

ប្រាក់ឧបត្ថម្ភក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារនេះបើកជូនកម្មករនិយោជិតនៅថ្ងៃទី១០ខែតុលា ឆ្នាំ២០២៤ នៅម៉ោងធ្វើការ ។

អង្គប្រជុំបានចប់វេលាម៉ោង ០៩ និង៣០នាទី នាថ្ងៃខែឆ្នាំដដែល ដោយភាពស្និតស្នាល និងយោគយល់គ្នាបំផុត ។

**ស្នាមមេដៃប្រតិភូបុគ្គលិក**

ភ្នំពេញ.ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២៤

**នាយកក្រុមហ៊ុន**

ឌីន លីង ហ្គាម៉ិន ឯ.ក
DIN LING GARMENT CO., LTD.

LIM KAI HENG